# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០១៩/០៧ របក.អគគ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មិថុនា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មិថុនា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជា អង្គភាពប្រតិបត្តិបានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវ ខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ក. ការងាររដ្ឋបាល

-ផ្ញើដីកាអមសេចក្តីថតចម្លងរបាយការណ៍ស្តីពីកិច្ចប្រជុំអង្គភាពសម្របសម្រួល អចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧ និងអញ្ជើញប្រជុំក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧

-ផ្ញើលិខិតស្នើអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង ១៤.៣០ នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំអនុក្រុមទី ១ ការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលា ការ នៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៧

-ផ្ញើលិខិតស្នើសុំចាត់តាំងអ្នកតំណាង ដើម្បីចូលរួមជាសមាជិកនៃក្រុមការងារជាន់ខ្ពស់ សម្រាប់ គម្រោងតុលាការគំរូ

-ផ្ញើសៀវភៅរបាយការណ៍នៃការសិក្សាស្រាវជ្រាវមួយស្តីពី "ជំនួយផ្នែកច្បាប់នៅកម្ពុជា ៖ ការ អនុវត្ត ការយល់ឃើញ និងតម្រូវការ" ជូនអ្នកពាក់ព័ន្ធ។

ខ. ការងារកំណែទម្រង់

-រៀបចំប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅតាមខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង

-រៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង ១៤ៈ៣០ នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី

-រៀបចំប្រជុំអនុក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ។

គ. ផ្សេងៗ

-ទទួលជួបក្រុមការងារ GTZ ដឹកនាំដោយលោក Luc de Meester ស្វែងយល់ពីគម្រោងអាទិភាព នៃកំណែទម្រង់ច្បាប់ និងតុលាការ

-ចូលរួមប្រជុំពិនិត្យរបាយការណ៍ស្តីពីភាពជឿនលឿនអភិបាលកិច្ច II ឆមាសទី II ២០០៦

-ចូលរួមប្រជុំពិនិត្យតម្លើងកាំបៀវត្សជូនមន្ត្រីរាជការ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលជួបគណៈប្រតិភូ DIHR ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និង DIHR

-ចូលរួមសិក្ខាសាលានៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការធ្វើអង្កេតលើសំណើសុំហិរញ្ញប្បទាន សហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុនសម្រាប់ឆ្នាំ ២០០៨

-ចូលរួមប្រជុំ CCJAP III នៅក្រសួងមហាផ្ទៃ នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៧

-ចូលរួមប្រជុំតុមូល ពិភាក្សាលើសេចក្តីព្រាងច្បាប់តុលាការពាណិជ្ជកម្ម នៅកម្មវិធីអភិវឌ្ឍន៍អង្គការ សហប្រជាជាតិ(UNDP) នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៧

-ចូលរួមសិក្ខាសាលាស្តីពីសេចក្តីព្រាងអនុក្រឹត្យបង្កើតមជ្ឈមណ្ឌលមជ្ឈត្តការពាណិជ្ជកម្ម នៅសណ្ឋាគារ HIMAWARI រៀបចំដោយក្រសួងពាណិជ្ជកម្ម។

២-សន្និដ្ឋាន

ក្នុងខែ មិថុនា ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមាន អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និងបានបំពេញ ការងារ យ៉ាងសកម្មក្នុងការរៀបចំមូលដ្ឋាន សម្រាប់ដំណើរការ ការងាររបស់ Sub-Group/TWG ដើម្បីរុញ ច្រានការ អនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ។

៣-ទិសដៅអនុវត្តក្នុងខែបន្ត

-គ្រោងរៀបចំប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៧

-ត្រៀមស្នើសុំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ឆមាស ទី១ ឆ្នាំ២០០៧ ពីបណ្តាក្រសួងពាក់ព័ន្ធ

-គ្រោងរៀបចំបទបង្ហាញតាមរយៈវីដេអូឆ្លងឆ្លើយ (Video Conference) ស្តីពីទស្សនាទាននៃ តុលាការគំរូ

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែ ទម្រង់ច្បាប់ និងតុលាការជាបន្ត នៅតាមខេត្ត

-បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងបញ្ជីគម្រោងតាមរយៈការប្រជុំពិភាក្សាតាម អនុក្រុម (Sub-group/TWG)។

*រាជធានីភ្នំពេញ ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០០៧*

អ្នកធ្វើរបាយការណ៍

ហ៊ឹង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង